# សារគន្លឹះ
# របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងឱកាសអបអរសាទរទិវា ASEM

ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២

*****

ដៃគូ ASEM ទាំងអស់ជាទីមេត្រី!

1. ស្របពេលដែលឆ្នាំនេះគឺជាខួបលើកទី២៦ នៃកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយសូមថ្លែងសារជូនពរដ៏កក់ក្តៅបំផុតជូនដល់ដៃគូ ASEM និងប្រជាជននៃទ្វីបទាំងពីរទាំងអស់របស់យើង សូមជួបតែសុភមង្គល វិបុលសុខ សុខភាពល្អ ព្រមទាំងការស្តារឡើងវិញពីជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយចីរភាព។ វាបានក្លាយជាការអនុវត្តរបស់យើងដែលកំណត់យកខែមីនា ដើម្បីប្រារព្ធទិវា ASEM ចាប់តាំងពីពេលបង្កើតវាឡើង ក្នុងឆ្នាំ២០១៦ នៅប្រទេសម៉ុងហ្គោលី រួចមក។
2. យើងអាចមានមោទនភាពចំពោះកំណត់ត្រារយៈពេល ២៦ឆ្នាំកន្លងមកនេះ នៃភាពជាដៃគូដ៏រឹងមាំរវាងអាស៊ី និងអឺរ៉ុប របស់ ASEM។ បច្ចុប្បន្ននេះ ASEM គឺជាក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការធំបំផុត នៅក្រៅអង្គការសហប្រជាជាតិ ដែលតំណាងឱ្យ ៦០% នៃចំនួនប្រជាជនពិភពលោក ៥៥% នៃពាណិជ្ជកម្មពិភពលោក ៦៥% នៃសេដ្ឋកិច្ចពិភពលោក និង ៧៥% នៃទេសចរណ៍ពិភពលោក។ ជាមួយនឹងការរួមចំណែកដ៏សំខាន់នេះ ASEM ពិតជាវេទិកាប្រកបដោយអត្ថន័យមួយនៅក្នុងកិច្ចការសកល ដែលមានពហុភាគីនិយមជាស្នូល។
3. កាលពីឆ្នាំមុន យើងមានឱកាសជាប្រវត្តិសាស្ត្រ និងកិត្តិយសដ៏អស្ចារ្យក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូល ASEM លើកទី១៣ (ASEM 13) ក្រោមប្រធានបទ "ការពង្រឹងពហុភាគីនិយមដើម្បីកំណើនរួមគ្នា" ហើយខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយដែលបានឃើញ មេដឹកនាំ ASEM ផ្តល់សារសំខាន់បំផុតទៅលើគុណតម្លៃស្នូលរបស់ ASEM ក៏ដូចជាទៅលើការប្តេជ្ញារបស់ខ្លួនធ្វើឱ្យប្រសើរឡើងវិញនូវពហុភាគីនិយមឆ្ពោះទៅរកអនាគតនៃកិច្ចសហប្រតិបត្តិការអាស៊ី-អឺរ៉ុប កាន់តែរឹងមាំ ប្រកបដោយចីរភាព បរិយាប័ន្ន និងថាមវន្ត។ ជាថ្មីម្តងទៀត ស្មារតីនៃភាពមិនផ្លូវការ ភាពបត់បែន ភាពជាដៃ

គូស្មើភាព កុងស៊ុងស៊ីស និងផលប្រយោជន៍ទៅវិញទៅមក បានលេចធ្លោយ៉ាងខ្លាំងនៅក្នុងដំណើរការនៃកិច្ចប្រជុំកំពូលទាំងមូលតែម្តង។

4. ថ្នាក់ដឹកនាំ ASEM បានបង្ហាញពីការចូលរួមយ៉ាងម៉ឺងម៉ាត់របស់ខ្លួននៅក្នុងការដោះស្រាយបញ្ហាប្រឈមសកល និងតំបន់ ដូចបានឆ្លុះបញ្ចាំងជាមួយនឹងសកម្មភាពជាសកលរបស់មេដឹកនាំ ASEM ប្រឆាំងនឹងជំងឺកូវីដ-១៩ និងការប្រែប្រួលអាកាសធាតុ ការប្តេជ្ញាចិត្តលើកកម្ពស់សុខភាព និងសុវត្ថិភាពសាធារណៈ ការយកចិត្តទុកដាក់លើការមានការងាររបស់យុវជន និងការលើកកម្ពស់សិទ្ធិអំណាចរបស់ស្ត្រី ព្រមទាំងការតាំងចិត្តដោះស្រាយកំណែទម្រង់អង្គការពាណិជ្ជកម្មពិភពលោក ក្នុងចំណោមបញ្ហាផ្សេងៗទៀត។ សំខាន់ជាងនេះទៅទៀត ថ្នាក់ដឹកនាំ ASEM ជាចុងក្រោយបានអនុម័តលើឯកសារលទ្ធផលសំខាន់ៗចំនួនបីគឺ៖ (១) សេចក្តីថ្លែងការណ៍របស់ប្រធានអង្គប្រជុំ ASEM13 (២) សេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញ ស្តីពីការស្តារសេដ្ឋកិច្ច-សង្គមឡើងវិញក្រោយជំងឺកូវីដ-១៩ និង (៣) ឯកសារផែនការអនាគតស្តីពីការតភ្ជាប់របស់ ASEM ។

5. ឯកសារលទ្ធផលទាំងនេះបានក្លាយជាសមិទ្ធផលជាប្រវត្តិសាស្ត្រថ្មីមួយនៅក្នុងកិច្ចសហប្រតិបត្តិការ ASEM ព្រមទាំងបានពង្រឹងសាមគ្គីភាព និងការប្តេជ្ញាចិត្តរួមគ្នារបស់យើង ដើម្បីបន្តរក្សា និងលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាព នៅអាស៊ី និងអឺរ៉ុប ក៏ដូចជាកសាងអនាគតមួយ ប្រកបដោយបរិយាប័ន្ន ចីរភាព និងមានភាពធន់សម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងអ្នកជំនាន់ក្រោយទៀតរបស់យើង។

6. ASEM ត្រូវតែតស៊ូបន្តទៀតសម្រាប់ទសវត្សរ៍បន្ទាប់ៗទៀតនាពេលខាងមុខនេះ និងទៅថ្ងៃអនាគត ដើម្បីធានាថា វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានធានាសម្រាប់ដៃគូ ASEM ទាំងអស់ និងប្រហែលជាអាចសម្រាប់បណ្តាប្រទេសផ្សេងទៀតនៅជុំវិញពិភពលោកផងដែរ។ ការប្តេជ្ញាចិត្តរបស់ ASEM ឆ្ពោះទៅកសាងសហគមន៍មួយប្រកបដោយភាពសុខដុមរមនា មានលក្ខណៈប្រកួតប្រជែង មានភាពធន់ និងចីរភាពសម្រាប់ប្រជាជននៅអាស៊ី និងអឺរ៉ុប នៅតែបន្តជាអាទិភាពកំពូលមួយរបស់ខ្លួន។

7. ដើម្បីសម្រេចបានគោលដៅខាងលើនេះ ដៃគូ ASEM ទាំងអស់ត្រូវតែសហការគ្នាឱ្យបានស្អិតរមួតនៅក្នុងគោលដៅរួមនេះ ដើម្បីធានាថា ពហុភាគីនិយមនឹងនាំមកនូវស្ថិរភាព និងវិបុលភាពដើម្បីកំណើនរួមគ្នា ព្រមទាំងធានាឱ្យបានថា ពហុភាគីនិយម នឹងដោះស្រាយបញ្ហាតំបន់ និងសកល ដែលមានស្រាប់ និង

កំពុងកើតមានឡើង ក្នុងគោលបំណងឈានទៅសម្រេចឱ្យបាននូវគោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០របស់អង្គការសហប្រជាជាតិ។

8. ក្នុងន័យនេះ កម្ពុជាបានត្រៀមខ្លួនរួចជាស្រេច និងទទ្ទឹងរង់ចាំបន្តអនុវត្តការងារយ៉ាងជិតស្និទ្ធជាមួយដៃគូ ASEM ទាំងអស់ ក៏ដូចជាភាគីពាក់ព័ន្ធនានា ក្នុងការអនុវត្តវិធានការផ្សេងៗ ដូចមានចែងនៅក្នុងឯកសារលទ្ធផល ASEM13 នាពេលថ្មីៗនេះ ដើម្បីបន្តជំរុញកិច្ចសហប្រតិបត្តិការ ASEM បន្ថែមទៀត ដោះស្រាយបញ្ហាដែលជាកង្វល់រួម ព្រមទាំងលើកស្ទួយទំនាក់ទំនងជាមិត្តភាពក្នុងចំណោមដៃគូទាំងអស់ឈានទៅដល់កម្រិតខ្ពស់ថ្មីមួយទៀត។

**សូមអរគុណ!**